


# ការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមអេឡិចត្រូនិច (EVV)
# គេហទំព័រ វិបផតថលសេវាអេឡិចត្រូនិច (ESP)
# ការចុះឈ្មោះអ្នកផ្តល់សេវា/អ្នកទទួលជំនួយ

www.etimesheets.ihss.ca.gov



សម្រាប់ជំនួយបន្ថែម សូមទាក់ទងទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS តាមលេខទូរស័ព្ទ (866) 376-7066 នៅពេលម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង 8am ទៅម៉ោង 5pm ហើយ ជ្រើសរើសយកជម្រើស វិបផតថលសេវាអេឡិចត្រូនិច ដើម្បីនិយាយជាមួយនឹងភ្នាក់ងារការិយាល័យសេវាកម្មផ្នែក ESP ។

## <u>ការចុះឈ្មោះអ្នកប្រើជាលើកដំបូង</u>

ប្រសិនបើ អ្នកកំពុងប្រើគេហទំព័រនេះជាលើកដំបូង អ្នកនឹងត្រូវចុះឈ្មោះសម្រាប់បង្កើតគណនីមួយ ។

**អ្នកនឹងត្រូវការព័ត៌មានដូចខាងក្រោមដើម្បីចុះឈ្មោះ ដូចដែលបានបង្ហាញនៅក្នុងឯកសារសំណុំរឿងសេវាការមើលថែទាំ (IHSS) របស់អ្នក:**

- ឈ្មោះរបស់អ្នក
- លេខ 9 ខ្ទង់ របស់អ្នកផ្តល់សេវា (ប្រសិនបើអ្នក ជាអ្នកផ្តល់សេវា) ឬលេខ 7 ខ្ទង់ របស់អ្នកទទួលជំនួយ (ប្រសិនបើអ្នក ជាអ្នកទទួលជំនួយ)
- ថ្ងៃខែឆ្នាំកំណើត
- លេខ 4 ខ្ទង់ ចុងក្រោយនៃលេខសូស្យាល់សឺគូរីទីរបស់អ្នក
- អាសយដ្ឋានអ៊ីម៉ែល ដែលមានសុពលភាព

**កំណត់ចំណាំ:** ទោះបីជាវាមិនត្រូវបានផ្តល់នូវយោបល់ក៏ដោយ អ្នកអាចប្រើអាសយដ្ឋានអ៊ីម៉ែលដូចគ្នាដើម្បីចុះឈ្មោះធ្វើជាអ្នកផ្តល់សេវា ហើយនិងអ្នកទទួលជំនួយរបស់អ្នក ។

ដើម្បីចូលប្រើ គេហទំព័រ វិបផលថលសេវាអេឡិចត្រូនិច សូមចូលទស្សនាគេហទំព័រ www.etimesheets.ihss.ca.gov

**<u>វាមាន 5 ដំណាក់ក្នុងដំណើរការចុះឈ្មោះ ដូចបានបង្ហាញខាងក្រោម:</u>**
**ដំណាក់ការទាំងនេះត្រូវបានតម្រូវឱ្យបំពេញតែម្តងប៉ុណ្ណោះ បន្ទាប់ពីនោះ**
**អ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវធ្វើ គឺចូល (login) ទៅបណ្តាញ**




**កំណត់ចំណាំ:** ដំណាក់ការនីមួយៗ នឹងត្រូវបានសម្គាល់ដោយពណ៌ទឹកក្រូច ដើម្បីចង្អុលបង្ហាញអំពីដំណាក់ការដែលអ្នកកំពុងស្ថិតនៅ ហើយវានឹងផ្លាស់ប្តូរទៅជាពណ៌បៃតងដើម្បីបង្ហាញដំណាក់ទីបញ្ចប់ ។

នៅផ្នែកខាងក្រោមនៃអេក្រង់របស់អ្នក អ្នកនឹងឃើញ drop-down list (បញ្ជីឈ្មោះទម្លាក់ចុះ) សម្រាប់ជម្រើសខាងភាសា ។ អ្នកអាចជ្រើសយកភាសាដែលអ្នកចង់បាន ដោយចុចលើ drop-down menu (ម៉ឺនុយទម្លាក់ចុះ) ។ នៅលើគេហទំព័រ វិបផតថលសេវាអេឡិចត្រូនិច គឺមានផ្តល់ជូនជាភាសា អង់គ្លេស អេស្ប៉ាញ ចិន និងអាមីនៀន ។




ប្រសិនបើអ្នកមានសំណួរផ្សេងៗ មុនពេលដែលអ្នកចាប់ផ្តើម មានតំណភ្ជាប់មួយនៅក្រោមតំណ Register Here (ចុះឈ្មោះនៅទីនេះ) សម្រាប់ “Registration Frequently Asked Questions” (សំណួរដែលបានសួរជាញឹកញាប់អំពីការចុះឈ្មោះ) ។ ដោយការចុចលើតំណនេះ វានឹងបើកឯកសារដែលផ្តល់ព័ត៌មានសម្រាប់អ្នក ដូចជា ព័ត៌មានអ្វីដែលអ្នកនឹងត្រូវការ ដើម្បីអាចបំពេញការចុះឈ្មោះរបស់អ្នកឱ្យបានចប់សព្វគ្រប់ ។

ចុចតំណ **Register Here (ចុះឈ្មោះនៅទីនេះ)** ដើម្បីចាប់ផ្តើមដំណើរការចុះឈ្មោះរបស់អ្នក ។




បន្ទាប់ពីការជ្រើសយកតំណ **Register Here** អ្នកនឹងត្រូវបាននាំយកទៅអេក្រង់ **Welcome (សូមស្វាគមន៍)** ។



នៅផ្នែកខាងលើនៃអេក្រង់ អ្នកនឹងឃើញសេចក្តីជូនដំណឹងដែលផ្តល់ព័ត៌មានអំពីអ្នកដែលអាចចូលរួម នៅលើគេហទំព័រនេះ ។

- ដើម្បីចាប់ផ្តើម អ្នកនឹងត្រូវជ្រើសថា តើអ្នកជា “Recipient” ឬជា “Provider” ។ បន្ទាប់ពីធ្វើការជ្រើសរើសរួចហើយ សូមចុចលើ **Begin Registration Process (ចាប់ផ្តើមដំណើរការចុះឈ្មោះ)** ។

អ្នកនៅពេលនេះ នឹងត្រូវបាននាំយកទៅអេក្រង់ 'Register' ។ អ្នកនឹងឃើញនៅផ្នែកខាងលើអេក្រង់របស់អ្នកនូវរបារធ្វើដំណើរទៅមុខនៃការចុះឈ្មោះរបស់អ្នក ។

របារនេះនឹងបង្ហាញអ្នកកន្លែងដែលអ្នកស្ថិតនៅ ដោយបំពេញ 5 ជំណាក់ការទាំងអស់បានយ៉ាងងាយស្រួលសម្រាប់ការចុះឈ្មោះបង្កើតគណនីរបស់អ្នក ។ អ្នកនឹងដឹងថាជំណាក់ការណាមួយដែលអ្នកកំពុងធ្វើ ពីព្រោះវានឹងត្រូវបានបន្លិចដោយពណ៌ទឹកក្រូច នៅក្នុងរបារធ្វើដំណើរទៅមុខរបស់អ្នក ។




សម្រាប់ **Step 1** (ជំណាក់ការទី 1) អ្នកនឹងត្រូវបញ្ចូលព័ត៌មានរបស់អ្នកប្រើ ។
នេះប្រាប់យើងអំពីអ្នក ហើយនឹងអនុញ្ញាតឱ្យប្រព័ន្ធត្រួតពិនិត្យលើព័ត៌មានរបស់អ្នកនៅក្នុងកម្មវិធី IHSS ឬ កម្មវិធី WPCS ។

អ្នកនឹងត្រូវបញ្ចូលព័ត៌មាន ដូចតទៅនេះ:

- ឈ្មោះ ផ្ទាល់ខ្លួន របស់អ្នក
- ឈ្មោះ ត្រកូល របស់អ្នក

- ថ្ងៃខែឆ្នាំកំណើត
- ប្រសិនបើអ្នកជាអ្នកផ្តល់សេវា អ្នកនឹងត្រូវបញ្ចូលលេខអ្នកផ្តល់សេវារបស់អ្នក ។ វាគួរតែជាតួលេខ 9 ខ្ទង់ ហើយដែលរកឃើញនៅលើក្រដាសស្នាមណាមួយរបស់អ្នកផ្តល់សេវា ដែលអ្នកបានទទួលដូចជា កន្ទុយសែកប្រាក់ខែពីពេលមុន ។

  **ឬ** ប្រសិនបើអ្នកជាអ្នកទទួលជំនួយ អ្នកត្រូវបញ្ចូលលេខអ្នកទទួលជំនួយ ។ វាគួរតែជាតួលេខ 7 ខ្ទង់ ហើយដែលអាចរកឃើញនៅលើក្រដាសស្នាមរបស់អ្នកទទួលជំនួយ ដែលអ្នកបានទទួលដូចជា សេចក្តីជូនដំណឹងអំពីការសម្រេចចិត្ត ។
- លេខ 4 ខ្ទង់ ចុងក្រោយនៃលេខសូស្យាល់សឺគួរីទីរបស់អ្នក

ប្រសិនបើអ្នកបានបញ្ចូលព័ត៌មានរបស់អ្នក ហើយទទួលបានសារដែលប្រាប់អ្នកថា ព័ត៌មាននោះមិនត្រូវគ្នានឹងឯកសារសំណុំរឿងរបស់យើងទេនោះ សូមទាក់ទងទៅការិយាល័យខោនធីផ្នែកកម្មវិធី IHSS ឬ ការិយាល័យ IHO ក្នុងតំបន់របស់អ្នក ។

**កំណត់ចំណាំ**: ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក មិនត្រូវបានផ្ទុកនៅក្នុងគេហទំព័រនេះទេ តែវាត្រូវបានប្រើសម្រាប់ការបញ្ជាក់លើកដំបូង ទៅលើអ្វីដែលត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធ IHSS ឬ WPCS ។

នៅពេលដែលអ្នកបានបំពេញដំណាក់ការទី 1 ចប់សព្វគ្រប់ហើយ សូមជ្រើសយកប៊ូតុង **Next (បន្ទាប់)** ។




អ្នកនឹងដឹងថាអ្នកបានបំពេញដំណាក់ការមួយនោះបានចប់សព្វគ្រប់ ពីព្រោះ ដំណាក់ការនោះនឹងផ្លាស់ប្តូរទៅជាពណ៌បៃតង នៅក្នុងរបារធ្វើដំណើរទៅមុខរបស់អ្នក។

សម្រាប់ **Step 2** (ជំណាក់ការទី 2), អ្នកនឹងបញ្ចូលព័ត៌មានដូចខាងក្រោមសម្រាប់គណនីថ្មីរបស់អ្នក:

- បង្កើតឈ្មោះអ្នកប្រើរបស់អ្នក:
    - ឈ្មោះអ្នកប្រើរបស់អ្នកគឺប្រកាន់យកអក្សរតូច ឬធំ និងអាចជាអ្វីដែលអ្នកចង់បាន វាត្រូវតែមានយ៉ាងហោចណាស់ 6 តួអក្សរ ទាំងនេះអាចជា តួលេខ តួអក្សរ ឬ និមិត្តសញ្ញា ។
    - ត្រូវឱ្យប្រាកដថា ឈ្មោះអ្នកប្រើរបស់អ្នកគឺជាអ្វីដែលអ្នកនឹងចងចាំ អ្នកនឹងត្រូវការវាដើម្បីបំពេញការចុះឈ្មោះរបស់អ្នក និង ដើម្បីចូលប្រើគណនីរបស់អ្នក ។
- បន្ទាប់មក បង្កើតលេខកូដសម្ងាត់របស់អ្នក:
    - លេខកូដសម្ងាត់របស់អ្នកគឺប្រកាន់យកអក្សរតូច ឬធំ និងត្រូវមានយ៉ាងហោចណាស់ 8 តួអក្សរ ហើយត្រូវមានរួមផ្សំជាមួយអក្សរ និងយ៉ាងហោចណាស់ចំនួនលេខពីរខ្ទង់ និង មិនមានតួអក្សរពិសេសទេ ។
    - ជាថ្មីម្តងទៀត វាគួរតែជាអ្វីដែលអ្នកអាចចងចាំ ពីព្រោះ អ្នកនឹងត្រូវការវាដើម្បីបំពេញការចុះឈ្មោះរបស់អ្នក និង ដើម្បីចូលប្រើគណនីរបស់អ្នក ។
- បញ្ជាក់លេខកូដសម្ងាត់របស់អ្នក
    - បញ្ចូលលេខកូដសម្ងាត់ដដែលនេះម្តងទៀត
- បន្ទាប់មកបញ្ចូលអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក ។
    - បញ្ចូលអាសយដ្ឋានអ៊ីម៉ែលដែលមានសុពលភាព ព្រោះអាសយដ្ឋានអ៊ីម៉ែលនេះ នឹងត្រូវយកមកប្រើសម្រាប់ការជូនដំណឹងនៅលើគណនីរបស់អ្នក
- វាត្រូវបានផ្តល់យោបល់ថាអ្នកផ្តល់សេវា ដែលគ្រាន់តែប្រើអាសយដ្ឋានអ៊ីម៉ែលដដែលសម្រាប់ការចុះឈ្មោះអ្នកទទួលជំនួយ ប្រសិនបើពួកគេជាអ្នកចុះហត្ថលេខាលើទំព័រកត់ត្រាពេលម៉ោងធ្វើការស្របច្បាប់ ឬ ពួកគេជាអ្នកតំណាងស្របច្បាប់ដែលតាងនាមជាឪពុកម្តាយរបស់អ្នកទទួលជំនួយដែលជាអនីតិជន ។
- ការបញ្ជាក់ទទួលស្គាល់អ៊ីម៉ែលរបស់អ្នក
    - បញ្ចូលអ៊ីម៉ែលដូចគ្នាម្តងទៀត




បន្ទាប់ពីបានបំពេញដំណាក់ការទី 2, សូមជ្រើសយកប៊ូតុង **Next** (បន្ទាប់)

សម្រាប់ **Step 3** (ជំណាក់ការទី 3) អ្នកនឹងត្រូវឆ្លើយ **Security Questions (សំណួរសុវត្ថិភាព)** មួយចំនួន។

អ្នកនឹងជ្រើសរើសសំណួរសុវត្ថិភាពចំនួនបី ពីបញ្ជីទម្លាក់ចុះ ។ ចុចព្រួញនៅផ្នែកខាងស្តាំនៃប្រអប់ ដើម្បីមើលសំណួរដែលអ្នកអាចជ្រើសរើសបាន ។

- ត្រូវប្រាកដថាចម្លើយរបស់អ្នក ចំពោះសំណួរសុវត្ថិភាពដែលអ្នកបានជ្រើសរើស គឺលំបាកសម្រាប់ឱ្យអ្នកដទៃស្មានដឹង ប៉ុន្តែ ងាយស្រួលសម្រាប់អ្នកចងចាំ ។ អ្នកនឹងប្រើសំណួរទាំងនេះដើម្បីបំពេញការចុះឈ្មោះរបស់អ្នក ក៏ដូចជាការកំណត់លេខកូដសម្ងាត់របស់អ្នកឡើងវិញផងដែរ ប្រសិនបើចាំបាច់ ។
- នៅពេលដែលអ្នកបានជ្រើសយក និង ឆ្លើយនូវសំណួរសុវត្ថិភាពទាំងបីរបស់អ្នករួចហើយ សូមជ្រើសយកប៊ូតុង **Next** ដើម្បីបញ្ចប់ជំណាក់ការទី 3 ។




<u>អ្នកនឹងកត់សម្គាល់នៅលើ Progress Bar របារធ្វើដំណើរទៅមុខរបស់អ្នកដែលថា អ្នកឈានដល់ **Step 4** (ជំណាក់ការទី 4 ) ហើយ</u>

- អ៊ីម៉ែលមួយនឹងត្រូវបានផ្ញើទៅអ្នក នៅអាសយដ្ឋានអ៊ីម៉ែលដែលមានសុពលភាព ដែលអ្នកបានផ្តល់ជូន ។ អ្នកនឹងត្រូវការបញ្ជាក់អាសយដ្ឋានអ៊ីម៉ែលរបស់អ្នក ។
- ចូលទៅអ៊ីម៉ែលដែលមកដល់របស់អ្នក និង ពិនិត្យមើលសារពីគេហទំព័រ IHSS ។

**កំណត់ចំណាំ**: ប្រសិនបើ អ្នកមិនឃើញសារនៅក្នុងប្រអប់សំបុត្ររបស់អ្នកនោះ សូមពិនិត្យមើលក្នុងប្រអប់សារឥតបានការ ឬ សារផ្សាយពាណិជ្ជកម្ម សម្រាប់អ៊ីម៉ែលនេះ ។




នេះគឺជាសារគំរូនៃអ្វីដែលអ្នកនឹងមើលឃើញលើសារអ៊ីម៉ែលរបស់អ្នក ដែលមានដូចតទៅនេះ:



នៅពេលដែលអ្នកទទួលបានអ៊ីម៉ែល អ្នកនឹងត្រូវបានគេស្នើសុំឱ្យបញ្ជាក់អាសយដ្ឋានអ៊ីម៉ែលរបស់អ្នក ។ ដើម្បីធ្វើដូចនេះ សូមធ្វើតាមដំណាក់ការទាំងអស់ក្នុងអ៊ីម៉ែល ដោយចុចលើតំណ **Verify my email address and login (ចូលបណ្តាញ និងផ្ទៀងផ្ទាត់អាសយដ្ឋានអ៊ីម៉ែលរបស់ខ្ញុំ)** ។

**កំណត់ចំណាំ**: វាជាការសំខាន់ក្នុងការបញ្ជាក់អាសយដ្ឋានអ៊ីម៉ែលរបស់អ្នកភ្លាមៗ ពីព្រោះ តំណចូលអាសយដ្ឋានអ៊ីម៉ែល អាចប្រើបានតែក្នុងរយៈពេលកំណត់ ប៉ុណ្ណោះ ។ ប្រសិនបើ តំណចូលអាសយដ្ឋានអ៊ីម៉ែលរបស់អ្នកផុតពេលកំណត់ អ្នកនឹងត្រូវចាប់ផ្តើមដំណើរការចុះឈ្មោះនេះ សាជាថ្មីម្តងទៀត ។

សូមអបអរសាទរ! ឥឡូវនេះ អ្នកបានបំពេញគ្រប់ដំណាក់ការទាំងប្រាំ សម្រាប់ការចុះឈ្មោះរបស់អ្នកចប់សព្វគ្រប់អស់ហើយ អ្នកត្រូវបានចុះឈ្មោះ និងមានគណនីជាមួយគេហទំព័រវិបផតថលសេវាអេឡិចត្រូនិចហើយ ។

សូមចងចាំថា អ្នកត្រូវរក្សាទុកឈ្មោះអ្នកប្រើ និងលេខកូដសម្ងាត់របស់អ្នកឱ្យមានសុវត្ថិភាព ហើយ មិនត្រូវចែករំលែកឈ្មោះអ្នកប្រើ ឬ លេខកូដសម្ងាត់របស់អ្នកឡើយ ។



## ទំព័រដើមដំបូងបង្អស់

នៅពេលដែលអ្នកបានបំពេញដំណើរការចុះឈ្មោះរបស់អ្នកចប់សព្វគ្រប់អស់ហើយ អ្នកនឹងត្រូវបាននាំយកទៅទំព័រដើមដំបូងបង្អស់ ។




សម្រាប់អ្នកផ្តល់សេវា អ្នកអាចធ្វើកិច្ចការដូចខាងក្រោម ដោយប្រើគណនីរបស់អ្នក:

- ដាក់ស្នើទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នក នៅក្នុងប្រព័ន្ធទំព័រកត់ត្រាពេលម៉ោងធ្វើការអេឡិចត្រូនិច
- ពិនិត្យមើលនូវប្រវត្តិការណ៍នៃការបង់ប្រាក់
- ចុះឈ្មោះចូលសម្រាប់ការដាក់ប្រាក់ចូលភ្លាមៗទៅក្នុងធនាគារ លើប្រព័ន្ធអនឡាញ
- និង ដាក់ពាក្យស្នើសុំសម្រាប់ពេលឈប់សម្រាកឈឺ លើប្រព័ន្ធអនឡាញ

**កំណត់ចំណាំ**: នៅពេលដែលអ្នកស្ថិតនៅទំព័រដើមដំបូងបង្អស់ អ្នកនឹងឃើញបញ្ជីឈ្មោះរបស់អ្នកទទួលជំនួយទាំងអស់ ដែលអ្នកផ្តល់សេវាឱ្យពួកគេ ។ ប្រសិនបើអ្នកទទួលជំនួយរបស់អ្នក មិនទាន់បានចុះឈ្មោះសម្រាប់វិបផតថលសេវាអេឡិចត្រូនិច (ESP) ឬ ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការ (TTS) នៅឡើយទេនោះ អ្នកនឹងឃើញសារយ៉ាងខ្លីមួយ ក្រោមឈ្មោះអ្នកទទួលជំនួយ ដែលប្រាប់អ្នកថា អ្នកទទួលជំនួយត្រូវចុះឈ្មោះ ។

សម្រាប់អ្នកទទួលជំនួយ អ្នកអាចធ្វើកិច្ចការដូចខាងក្រោម ដោយប្រើគណនីរបស់អ្នក:

- ពិនិត្យឡើងវិញនូវទំព័រកត់ត្រាពេលម៉ោងធ្វើការតាមអេឡិចត្រូនិចរបស់ អ្នកផ្តល់សេវារបស់អ្នក
- យល់ព្រម ឬ បដិសេធទំព័រកត់ត្រាពេលម៉ោងធ្វើការអេឡិចត្រូនិចរបស់ អ្នកផ្តល់សេវារបស់អ្នក
- ពិនិត្យមើលប្រវត្តិការណ៍នៃទំព័រកត់ត្រាពេលម៉ោងធ្វើការអេឡិចត្រូនិចរបស់ អ្នកផ្តល់សេវារបស់អ្នក